# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




Asian International Justice Initiative (AIJI), a project of East-West Center and UC Berkeley War Crimes Studies Center

*[...]ពុំមានការចូលរួមពីជនរងគ្រោះ ពិតជាលំបាកក្នុងការឈ្វេងយល់ពីការជំនុំជម្រះចំពោះបទឧក្រិដ្ឋ*
*ដែលប៉ះពាល់ដល់គ្រប់គ្រួសារ និងគ្រប់ភូមិភាគនៅក្នុងប្រទេសកម្ពុជា និងឧក្រិដ្ឋកម្ម*
*ដែលបាត់ដានជាង ៣០ឆ្នាំមកហើយ។ គ្មាននរណាប្រសើរជាងជនរងគ្រោះទេ*
*ដែលអាចរៀបរាប់រឿងរ៉ាវបានយ៉ាងច្បាស់លាស់ ទាមទារស្វែងរកការពិត*
*និងស្នើសុំឲ្យមានសាលក្រមប្រកបដោយយុត្តិធម៌?*

លោកស្រី **អេលីហ្សាប៊ែត ស៊ីម៉ុណូហ្វត** ជាសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី

## I. ទិដ្ឋភាពទូទៅ

នៅក្នុងអនុស្សារណៈចុះថ្ងៃទី២៣ កញ្ញា ២០១១ អង្គជំនុំជម្រះសាលាដំបូង បានធ្វើការកត់សម្គាល់មួយចំនួន អំពីភាពមិនត្រឹមត្រូវនៃសំណើសុំសំណង ដែលទាមទារដោយសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី កាលពីសវនាការបឋមថ្ងៃទី២៩ មិថុនា ២០១១[i]។ តុលាការបានសម្រេចកំណត់ឲ្យមានសវនាការពិសេសមួយ ក្នុងការលើកឡើងអំពីទម្រង់នៃការទាមទារសំណង[ii] និងផ្តល់ឱកាសឲ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណី អាចដាក់ "ព័ត៌មានបន្ថែម ការធ្វើបច្ចុប្បន្នភាព និងការកែប្រែលើទម្រង់សំណងដែលបានផ្តល់ជូនតុលាការនាអំឡុងពេលសវនាការបឋម"[iii] យោងតាមវិធានផ្ទៃក្នុង វិធាន ៨០ស្ទួន (៤) និង វិធាន ២៣ស្ទួនបួន (៣)(ខ)។ អង្គជំនុំជម្រះ បានកំណត់ផ្តល់ពេល បីម៉ោង ដល់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋ

ប្បវេណី ធ្វើសេចក្តីថ្លែងអំពីសំណើសុំសំណង ព្រមទាំងផ្តល់ឱកាសសមស្របដល់ភាគីនានាក្នុងការតទល់។ របាយការណ៍នេះ នឹងផ្តល់ជាសេចក្តីសង្ខេប និងកិច្ចអធិប្បាយពន្យល់អំពីសវនាការពិសេស ស្តីពីទម្រង់ជាក់លាក់នៃការទាមទារសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលប្រព្រឹត្តទៅនៅថ្ងៃទី១៩ តុលា ២០១១។

សហមេធាវីនាំមុខ រួមនឹងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនរូប[iv] បានថ្លែងថា អង្គជំនុំជម្រះសាលាដំបូង ខកខានមិនបានផ្តល់នូវនិយមន័យ ឬ ស្តង់ដារជាក់លាក់ ទាក់ទងនឹងតម្រូវការនៃទម្រង់ស្នើសុំសំណងនោះទេ ។ តាមរយៈការលើកឡើងអំពីការផ្តល់សំណង នៅតុលាការអន្តរជាតិនានា ភាគីទាំងឡាយបានអះអាងថា អង្គជំនុំជម្រះបានអនុម័តនូវតម្រូវការដោយមិនជាក់លាក់អំពីទម្រង់នៃសំណង។ ម្យ៉ាងទៀតភាគីបានពន្យល់ថា ផែនការរៀបចំទម្រង់សំណង គឺជាកិច្ចប្រឹងប្រែងរួម ដែលត្រូវការចាំបាច់នូវពេលវេលាក្នុងការពិគ្រោះយោបល់ជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីជាង ៤000នាក់ នៅក្នុងសំណុំរឿង០០២។ ទោះបីជាជួបប្រទះបញ្ហាយ៉ាងណាក៏ដោយ ក៏មេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានដាក់ជូនអង្គជំនុំជម្រះនូវទម្រង់សំណងជាក់លាក់មួយចំនួននាកំឡុងពេលសវនាការនោះ។

## II. **ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី**

ផ្នែកនេះនឹងលើកបង្ហាញអំពីចំណុចសំខាន់ៗ ដែលសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានពិភាក្សា រួមមាន ៖ (ក)ទឡ្ហីករណ៍ជំទាស់ទៅនឹងការកម្រិតទម្រង់នៃការទាមទារសំណង ដែលលើកឡើងដោយអង្គជំនុំជម្រះសាលាដំបូង (ខ)ព័ត៌មានលម្អិតអំពីការទាមទារសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី (គ)សេចក្តីថ្លែងការណ៍របស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី អំពីដែនសមត្ថកិច្ចរបស់ អ.វ.ត.ក ក្នុងការផ្តល់សំណង និង (ឃ)សារសំខាន់នៃសំណងប្រកបដោយអត្ថន័យ។

### ក. លក្ខខណ្ឌតម្រូវសម្រាប់ការកំណត់ការទាមទារសំណងដំបូង

កំឡុងពេលធ្វើសេចក្តីថ្លែងការណ៍ផ្ទាល់មាត់ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី **ម៉ាទីនហ្សាក់កាង** បានលើកឡើងនូវការជំទាស់មួយចំនួនចំពោះអនុស្សារណះរបស់អង្គជំនុំជម្រះសាលាដំបូង កាលពីថ្ងៃទី២៣ កញ្ញា។ **ទីមួយ** លោកស្រីបានសំអាងថា អង្គជំនុំជម្រះបានដាក់បន្ទុកមិនសមស្របចំពោះដើមបណ្តឹងរដ្ឋប្បវេណីក្នុងការកំណត់ទម្រង់សំណងឲ្យបានជាក់លាក់ តែបែរជាពុំបានផ្តល់ពេលវេលាគ្រប់គ្រាន់ក្នុងផ្លាស់ប្តូរយោបល់ជាមួយដើមបណ្តឹងចំនួន ១,៧២៨នាក់ ទៀត ដែលទើបតែទទួលស្គាល់ដោយអង្គបុរេជំនុំជម្រះ នាថ្ងៃទី២៤ មិថុនា ២០១១។ **ទីពីរ** លោកស្រី **ហ្សាក់កាង** បានអះអាងថា វិធាន ២៨ ស្ទួន នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក មិនបានតម្រូវឲ្យមានការដាក់កំណត់ទម្រង់ជាក់លាក់នៃការទាមទារសំណងនៅក្នុងដំណាក់កាលចាប់ផ្តើមដំបូងនោះទេ បើទោះជាមានការណែនាំឲ្យដើមបណ្តឹងរដ្ឋប្បវេណីផ្តល់នូវការកំណត់បឋមនៃការទាមទាររបស់ខ្លួនក៏ដោយ។ ស្ទើរតែគ្រប់ពេល លោកស្រីមេធាវីបានជំទាស់តវ៉ាថា នៅក្នុងវិធានផ្ទៃក្នុងពុំបានចែង និងអនុញ្ញាតឲ្យអង្គជំនុំជម្រះពាក់ព័ន្ធក្នុងការកំណត់ទម្រង់នៃការទាមទារសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។

លោកស្រី **ហ្សាក់កាង** បានលើកហេតុផលថា វាមិនទាន់ដល់ពេល និងមិនមានហេតុផលណា ដែលតម្រូវឲ្យដាក់ទម្រង់នៃការទាមទារសំណងលម្អិតនៅក្នុងដំណាក់កាលនេះ។ បញ្ហាផ្លូវច្បាប់មួយចំនួននៅក្នុងបណ្តឹងឧទ្ធរណ៍នៃសំណុំរឿង

០០១ ស្តីពីសំណង (ដែលដូចគ្នាទៅនឹងសំណើសុំសំណងនៃសំណុំរឿង០០២) កំពុងតែរង់ចាំសេចក្តីវិនិច្ឆ័យពីអង្គជំនុំជម្រះនៃតុលាការកំពូលនៅឡើយ។ លោកស្រី **ហ្សាក់កាង** បានកត់សម្គាល់ថា ដើមបណ្តឹងរដ្ឋប្បវេណីមានចំណាប់អារម្មណ៍ថា អង្គជំនុំជម្រះសាលាដំបូងនៃសំណុំរឿង០០១ បានអនុម័តយកការបកស្រាយមិនសមស្រប អំពី "សំណងសមូហភាព និង សំណងផ្លូវចិត្ត" ព្រមទាំងខកខានមិនបានបញ្ជាក់អំពីហេតុផលនៃការបដិសេធមិនផ្តល់សំណងតាមការទាមទារ។ ពួកគេសង្ឃឹមថា សេចក្តីសម្រេចនៃបណ្តឹងឧទ្ធរណ៍ នឹងចូលរួមចំណែកដល់វិសាលភាពសំណងនៅក្នុងសំណុំរឿងបច្ចុប្បន្ន។

មេធាវីដើមបណ្តឹងរដ្ឋប្បវេណី **សំ សុខគង់** បានថ្លែងរំឭកសារជាថ្មីដល់អង្គជំនុំជម្រះថា ពង្រាងនៃទម្រង់ទាមទារសំណងដែលឆ្លុះបញ្ចាំងពីផលប្រយោជន៍របស់ជនរងគ្រោះ គឺជាការងារដ៏ស្មុគស្មាញមួយ។ លោកមេធាវីបានពន្យល់ថា ករណីចាំបាច់តម្រូវឲ្យមានការពិគ្រោះយោបល់ និងកិច្ចសហការរវាងដើមបណ្តឹងរដ្ឋប្បវេណី សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី អង្គភាពគាំទ្រជនរងគ្រោះនៃ អ.វ.ត.ក និងអង្គការមិនមែនរដ្ឋាភិបាលដែលជួយជ្រោមជ្រែងដល់ជនរងគ្រោះ។ លោកមេធាវីបន្តសង្កត់ធ្ងន់ថា អង្គជំនុំជម្រះមិនបានបញ្ជាក់ឲ្យច្បាស់អំពីលក្ខខណ្ឌតម្រូវ "អំពីការកំណត់ជាក់លាក់នៃទម្រង់សំណង" ហើយក៏ពុំមានការកំណត់ណាមួយអំពីនិយមន័យនៃសំណងនៅក្នុងវិធាននានា ឬយុត្តិសាស្ត្រ ឬមូលដ្ឋានច្បាប់ផ្សេងៗ បញ្ជាក់អំពីលក្ខខណ្ឌផ្លូវច្បាប់ឡើយ។ លើសពីនេះទៀត មេធាវី **សំ សុខគង់** បានអះអាងថា ការកម្រិតនៃការទាមទារដែលអង្គជំនុំជម្រះបានតម្រូវឲ្យបំពេញ រួមមានដូចជា ការកំណត់ពីទីតាំងជាក់លាក់សម្រាប់បូជនីយដ្ឋាន ការកំណត់អំពីមាតិកាពិតប្រាកដបញ្ចូលក្នុងកម្មវិធីអប់រំ ការចំណាយចាំបាច់នានា និងប្រភពមូលនិធិ...ជាដើម ពុំមានហេតុផលសមរម្យ និងពុំមានការគាំទ្រពីយុត្តិសាស្ត្រអន្តរជាតិនោះទេ។

មេធាវី **សំ សុខគង់** បានស្នើឡើងថា អង្គជំនុំជម្រះគួរយោងទៅលើការអនុវត្តន៍របស់តុលាការអន្តរជាតិនានា ដែលបានសម្រេចទាក់ទងនឹងបញ្ហាសំណង។ ឧទាហរណ៍ លោកមេធាវីបានដកស្រង់វិធាននៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលបញ្ជាក់ថា ពុំមានកំណត់ប្រើពាក្យ "ជាក់លាក់" និង "ការធ្វើឲ្យជាក់លាក់" នោះទេ។ ខណៈដែលពុំមានយុត្តិសាស្ត្រ ដែលចង្អុរបង្ហាញពីការបកស្រាយរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិពាក់ព័ន្ធនឹងបញ្ហាសំណង ដូចនេះត្រូវអនុវត្តតាមវិធាននៃតុលាការព្រហ្មទណ្ឌអន្តរជាតិ គឺ "ការមិនបញ្ជាក់ពីការកម្រិតឲ្យជាក់លាក់នៃសំណង"។ ដូចគ្នានេះដែរ សេចក្តីសម្រេចរបស់តុលាការសិទ្ធិមនុស្សអន្តរអាមេរិក ក៏មិនបានឆ្លុះបញ្ចាំងអំពីការកំណត់ជាក់លាក់នៃសំណង ។ មេធាវី **សំ សុខគង់** បានលើកទឡ្ហីករណ៍ថា តុលាការសិទ្ធិមនុស្សអន្តរអាមេរិក បានសម្រេចផ្តល់សំណងដល់ជនរងគ្រោះដោយមិនតម្រូវឲ្យពួកគេបំពេញកាតព្វកិច្ចក្នុងការបញ្ជាក់ឲ្យបានជាក់លាក់ អំពីចំនួនពិតប្រាកដនៃ បូជនីយដ្ឋាន ទីតាំងចងចាំ ការប៉ាន់ប្រមាណតម្លៃនានា និងព័ត៌មានលម្អិតផ្សេងៗនៃការទាមទារសំណងនោះឡើយ។ លោកមេធាវីបានដកស្រង់ករណី **ម៉ាពីរីពាន និង កូឡុំប៊ៀរ៍** *(Mapiripan Massacre v. Colombia)*[v] ដែលតុលាការសិទ្ធិមនុស្សអន្តរអាមេរិក បានពិចារណាសម្រេចផ្តល់សំណងដូចខាងក្រោម ៖

> ...តាមរយៈស្ថានទម្ងន់នៃអង្គហេតុនៅក្នុងសំណុំរឿង ស្ថានភាពនិរទណ្ឌភាព និងស្ថានភាពការឈឺចាប់ដែលបានកើតឡើងលើជនរងគ្រោះ ការផ្លាស់ប្តូរលក្ខខណ្ឌអត្ថិភាព និងផលវិបាកទាក់ទងនឹងប្រាក់កាស (ឬមិនទាក់ទងនឹងប្រាក់កាស) តុលាការយល់ឃើញថា ចាំបាច់បង្គាប់ឲ្យបង់សំណងការខូចខាតដល់ព្យសនៈកម្ម ដោយយុត្តិធម៌[vi] ទោះមិនបានគិតជាប្រាក់កាសក្តី។

នៅក្នុងករណីខាងលើ តុលាការសិទ្ធិមនុស្សអន្តរអាមេរិក បានបង្គាប់បញ្ជាឲ្យសាងសង់វិមានអនុស្សាវរីយ៍មួយ[vii] ដោយមិនចាំបាច់តម្រូវឲ្យជនរងគ្រោះកំណត់នូវទម្រង់សំណងលម្អិតនោះទេ។ ដូចគ្នានេះដែរ មេធាវី **សំ សុខគង់** បានស្នើសុំថា ដើមបណ្តឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក មិនគួរទទួលបន្ទុកក្នុងការបញ្ជាក់ អំពីកម្រិតនៃទម្រង់សំណង ដែលតម្រូវដោយអង្គជំនុំជម្រះ។

**ខ. សំណើសុំសំណង**

ថ្វីត្បិតតែមាន ខដាក់លក្ខខណ្ឌ និងទទ្បីករណ៍ លើកឡើងដោយសហមេធាវីនាំមុខ និងក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីដូចខាងលើក៏ដោយ ក៏ពួកគេនៅតែអនុវត្តតាមសំណើរបស់អង្គជំនុំជម្រះ និងបានបង្ហាញអំពីទម្រង់សំណើទាមទារសំណងរបស់ខ្លួន។ មេធាវីបានបញ្ជាក់អំពីការវិវត្តន៍នៃទម្រង់សំណងរបស់ខ្លួន គឺបានពិគ្រោះយោបល់ និងសម្របសម្រួលជាមួយដើមបណ្តឹងរដ្ឋប្បវេណី មេធាវីដើមបណ្តឹងរដ្ឋប្បវេណី អង្គភាពគាំពារជនរងគ្រោះ និងអង្គការជាដៃគូផ្សេងៗទៀត។ ទម្រង់សំណងត្រូវបានកំណត់ជាបួនប្រភេទ ដាក់ជូនអង្គជំនុំជម្រះ រួមមាន ៖ (១) ការរំឭកការចងចាំ និង បូជនីយដ្ឋាន (២) ការស្តារនីតិសម្បទា (៣) ការចងក្រងឯកសារនិងការអប់រំ និង (៤) សំណើទាមទារសំណងផ្សេងៗទៀត។

**១. ការរំឭកការចងចាំ និង បូជនីយដ្ឋាន**

សហមេធាវីនាំមុខលោក **ពេជ អង្គ** បានពន្យល់ថា ជាចម្បង ទម្រង់នៃសំណងនេះ គឺមានបំណងចង់រំឭកដល់ការចងចាំ និងផ្តល់ការគោរពដល់ជនរងគ្រោះដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ក៏ដូចជា "ដំណើរការជានិមិត្តរូបសម្រាប់ព្យាបាលទុក្ខសោកសង្រេង និងការឆ្លុះបញ្ចាំងអំពីរឿងរ៉ាវដែលបានកើតឡើង"។ ខាងក្រោម គឺជាការកំណត់ទម្រង់ជាក់លាក់នៃការរំឭកការចងចាំ និងបូជនីយដ្ឋាន រួមមាន ៖

***១.១ ការសម្របសម្រួលឲ្យមានទិវារំឭកថ្នាក់ជាតិ ឬ ទិវាចងចាំ ៖*** នេះជាការតស៊ូមតិមួយ ដែលស្វែងរកការបង្កើតឲ្យមានទិវាចងចាំថ្នាក់ជាតិ និងអន្តរជាតិ ដើម្បីទទួលស្គាល់ការឈឺចាប់របស់ជនរងគ្រោះនៃរបបខ្មែរក្រហម។ ដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំឲ្យមានទិវានេះឡើង អាចនៅក្នុងកំឡុងពេល ឬក្រោយពេលបុណ្យភ្ជុំបិណ្ឌ ឬនៅថ្ងៃទី១៧ ខែមេសា ឬ ថ្ងៃទី២០ ខែឧសភា។ ជនរងគ្រោះក៏បានស្នើឲ្យមានទិវាចងចាំផ្សេងទៀតសម្រាប់ជនរងគ្រោះពីបទឧក្រិដ្ឋជាក់លាក់មួយចំនួន។ គម្រោងនេះតម្រូវឲ្យមានអន្តរកម្មជាមួយរដ្ឋាភិបាល ឬ ជាមួយភ្នាក់ងារអន្តរជាតិផ្សេងៗ ក្នុងការអនុវត្តន៍។

***១.២ ចេតិយ និងវិមានសាមគ្គីបែបសាសនា ៖*** ចេតិយបែបពុទ្ធសាសនា រួមជាមួយ សំណង់ដែលមិនតំណាងឲ្យនិកាយសាសនាជាក់លាក់ណាមួយ នឹងអាចធ្វើការរំឭក និងសម្តែងការគោរពដល់ជនរងគ្រោះនៃរបបខ្មែរក្រហម និងអាចផ្តល់ឱកាសដល់ជនជំនាន់ក្រោយនៅតែចងចាំជនរងគ្រោះជានិរន្តរន៍។ ការអនុវត្តគម្រោងទាំងនេះ ទាមទារឲ្យមានការទទួលស្គាល់ និងយល់ព្រមពីអាជ្ញាធរដែនដី ដែលទីតាំងនោះស្ថិតនៅ ដើម្បីធ្វើការសាងសង់សំណង់ទាំងនេះ។ កំណត់សម្គាល់ ការចរចារ និងការទំនាក់ទំនងជាមួយអាជ្ញាធរមួយចំនួនបានកំពុងដំណើរការប្រព្រឹត្តទៅជាបណ្តើរៗ។

***១.៣ ពិធីបុណ្យរំឭក បន្ទាប់ពីការប្រកាសសាលក្រម និងក្នុងឱកាសផ្សេងទៀត ៖*** គម្រោងនេះមានបំណងចង់ឲ្យដើមបណ្តឹងរដ្ឋប្បវេណីជួបជុំគ្នា ដើម្បីថ្លែងអំពីទុក្ខសោកសង្រេងនៃភាពឈឺចាប់ និងបង្ហាញអំពីការយល់ឃើញ

រៀងៗខ្លួនទៅលើសាលក្រមរបស់តុលាការ។

***១.៤ ការរៀបចំ និងការអភិរក្សទីតាំងឧក្រិដ្ឋកម្ម ៖*** ការអភិរក្សទីតាំងឧក្រិដ្ឋកម្ម គឺមានសារសំខាន់ក្នុងការធានារក្សាភស្តុតាងនៃភាពយង់ឃ្នងដែលបានកើតមានឡើង។ រាជរដ្ឋាភិបាលបានចេញសារាចរណែនាំមួយក្នុងការអភិរក្សទីតាំងទាំងនេះ ដូចជា វាលពិឃាតជើងឯក ចំណែកឯសហមេធាវីនាំមុខបានកំពុងកំណត់ទីតាំងឧក្រិដ្ឋកម្មផ្សេងទៀតដោយមានការសហការណ៍ជាមួយអង្គភាពគាំទ្រជនរងគ្រោះ ដែលនេះមានន័យថាជាការសម្របសម្រួលមួយជាមួយអាជ្ញាធររដ្ឋាភិបាល។

**២. គម្រោងស្តារនីតិសម្បទា**

***២.១ ការលើកកម្ពស់សុខភាពផ្លូវចិត្ត និងរាងកាយ ៖*** គម្រោងនេះមានបំណងកសាងមណ្ឌលសុខភាពសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានបញ្ហាផ្លូវកាយ និងផ្លូវចិត្ត ដោយសារតែរងការឈឺចាប់ក្នុងរបបខ្មែរក្រហម។ គម្រោងនេះអាចអនុវត្តបាន ទាល់តែមានការសម្របសម្រួលជាមួយអង្គការនានា ដូចជា អង្គការចិត្តសង្គម អន្តរវប្បធម៌ (ធីភីអូ) ជាដើម។

***២.២ ការបង្កើតក្រុមជួយខ្លួនឯង ៖*** គឺជាគម្រោងមួយ ដែលបង្កើតក្រុមលើកទឹកចិត្តជួយដល់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការបញ្ចេញនូវអារម្មណ៍របស់ខ្លួន ការឈឺចាប់ និងបទពិសោធន៍ ព្រមទាំងអាចជួយពួកគាត់ឈានទៅរកការផ្សះផ្សាចិត្ត។ គម្រោងនេះមានប្រយោជន៍ជាពិសេសសម្រាប់ជនរងគ្រោះដោយអំពើហិង្សាផ្លូវភេទ និងការរៀបអាពាហពិពាហ៍ដោយបង្ខំ។ អង្គការធីភីអូ បានបង្កើតនូវកម្មវិធីស្រដៀងគ្នានេះដែរ ប៉ុន្តែ វាទាមទារឲ្យមានកិច្ចសហការបន្ថែមពីអង្គភាពគាំទ្រជនរងគ្រោះ អង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរការីដទៃទៀត។

**៣. ការចងក្រងឯកសារ និងការអប់រំ**

គម្រោងចងក្រងឯកសារ និងការអប់រំ មានគោលបំណងចង់ឲ្យសាធារណជនមានការយល់ដឹងអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងបទពិសោធន៍របស់ជនរងគ្រោះក្នុងសម័យនោះ។ គម្រោងនេះ គឺដើម្បីឲ្យមនុស្សជំនាន់ក្រោយក្រឡេកទៅមើលអ្វីដែលបានកើតឡើង និងទប់ស្កាត់មិនឲ្យមានមហាវិនាសកម្មដូចនេះកើតជាថ្មីម្តងទៀត។ ដើមបណ្តឹងរដ្ឋប្បវេណី ជំរុញឲ្យមានការបញ្ចូលនូវក្នុងកម្មវិធីសិក្សារបស់ក្រសួងអប់រំ អំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងដំណើរការរបស់សាលាក្តី តាមរយៈកម្មវិធីដូចខាងក្រោម៖

***៣.១ មណ្ឌលឯកសារ សារមន្ទីរ និងបណ្ណាល័យ ៖*** ដើមបណ្តឹងរដ្ឋប្បវេណី បានស្នើឲ្យមានការបង្កើតស្ថាប័នដែលនឹងផ្តល់ជាកន្លែងសម្រាប់ឲ្យសាធារណជនចូលស្វែងរកឯកសារ ព្រមទាំងជាកន្លែងអាចផ្តល់ការអប់រំដល់ប្រជាពលរដ្ឋខ្មែរអំពីរបបខ្មែរក្រហម និងអំពីដំណើរការជំនុំជម្រះនៅ អ.វ.ត.ក ។ មជ្ឈមណ្ឌលឯកសារទាំងនេះនឹងរក្សាទុកឯកសារ អភិរក្ស និងធ្វើការផ្សព្វផ្សាយ ក្នុងគោលបំណងជាប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណី និងមនុស្សជំនាន់ក្រោយ។

***៣.២ បញ្ជីឈ្មោះរបស់ជនរងគ្រោះ ៖*** គម្រោងនេះស្វែងរកឲ្យមានការបង្កើតឯកសារមួយដែលមានឈ្មោះថា “ក្រាំងមាស” សម្រាប់រំឭកដល់ជនរងគ្រោះ។ បញ្ជីនេះនឹងបើកឱកាសដល់ជនរងគ្រោះទាំងឡាយក្នុងការចុះឈ្មោះ និងរួមចំណែកចែករំលែករឿងរ៉ាវរបស់ខ្លួន។ ក្រៅពីការបោះពុម្ពជាសៀវភៅ ឯកសារនេះអាចស្វែងរកបានតាមរយៈគេហទំព័រនៃតុលាការទូរនិម្មិតរបស់ អ.វ.ត.ក។

***៣.៣ ការបោះផ្សាយឈ្មោះដើមបណ្ដឹងនៅក្នុងសេចក្ដីសម្រេចរបស់តុលាការ*** ៖ គម្រោងនេះមានបំណងក្នុងការបោះផ្សាយឈ្មោះ ទីកន្លែងកំណើត លំនៅដ្ឋានបច្ចុប្បន្ន និងមុខរបរ របស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រមទាំងចង់ឲ្យមានការចែកផ្សាយទូទាំងផ្ទៃប្រទេស។

***៣.៤ មជ្ឈមណ្ឌលព័ត៌មានវប្បធម៌*** ៖ ដើមបណ្ដឹងបានស្នើឲ្យមានការបង្កើតមជ្ឈមណ្ឌលផ្សព្វផ្សាយព័ត៌មានអំពីព្រឹត្តិការណ៍ក្នុងសម័យខ្មែរក្រហម ព្រមទាំងអំពីវប្បធម៌និងប្រពៃណីរបស់ប្រជាជនកម្ពុជានៅមុនរបបនេះបានកើតឡើង។ គម្រោងនេះបានចាប់ផ្ដើមដំណើរការហើយ គឺស្ថិតក្រោមការគ្រប់គ្រងរបស់អង្គការជំនួយផ្នែកច្បាប់នៅកម្ពុជា ដោយមានការឧបត្ថម្ភពីស្ថានទូតបារាំង។

***៣.៥ មជ្ឈមណ្ឌលអភិរក្សវប្បធម៌ជនជាតិចាម*** ៖ ការវាយប្រហាររបស់ខ្មែរក្រហមទៅលើជនជាតិចាម (ខ្មែរមូស្លីម) ស្ទើរតែធ្វើឲ្យបាត់បង់វប្បធម៌ និងភាសារបស់ជនជាតិនេះ។ គម្រោងនេះ ស្វែងរកការអភិរក្សវប្បធម៌ជនជាតិចាម តាមរយៈការបង្កើតមជ្ឈមណ្ឌលវប្បធម៌មួយនៅក្នុងខេត្តកំពង់ចាម។

**៤. សំណើទាមទារសំណងផ្សេងទៀត**

***៤.១ ការបង្កើតគម្រោងមូលនិធិ (Trust Fund)*** ៖ ថ្វីត្បិតតែ អង្គជំនុំជម្រះសាលាដំបូងបានជំទាស់ទៅនឹងសំណូមពររបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០១ អំពីការបង្កើតមូលនិធិស្ម័គ្រចិត្ត[viii] ក៏សហមេធាវីនាំមុខបានគូសបញ្ជាក់ឡើងវិញ អំពីការដាក់បញ្ចូលមូលនិធិនេះនៅក្នុងសំណើសុំរបស់ខ្លួន នៅក្នុងករណី ០០២។ មេធាវីបានលើកផ្ទុយពីសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះថា សំណើនេះមិនប្រាសចាកពីក្របខណ្ឌសំណងរបស់ អ.វ.ត.ក នោះទេ។ មេធាវីបានបន្តសង្កត់ធ្ងន់ថា គម្រោងនេះមិនចាំបាច់ហៅថា "គម្រោងមូលនិធិ" ដែលអាចភ័ន្តច្រលំជាមួយមធ្យោបាយនៃការផ្ដល់សំណងបែបហិរញ្ញវត្ថុ។ ផ្ទុយមកវិញ គម្រោងនេះអាចសំដៅទៅដល់ "គម្រោងមូលនិធិបង្កើតសំណងសមូហភាព និងសំណងផ្លូវចិត្ត" ដែលនឹងប្រើប្រាស់មូលនិធិនេះក្នុងការអនុវត្តន៍ផែនការសំណង។

***៤.២ ការបង្កើតស្ថាប័នអនុវត្តន៍*** ៖ សហមេធាវីនាំមុខក៏បានស្នើឲ្យមានការបង្កើតអង្គភាពមួយអនុវត្តផែនការសំណង ដែលនឹងងផ្តល់ដោយតុលាការ ជាពិសេស បន្ទាប់ពី អ.វ.ត.ក បានបញ្ចប់អាណត្តិរបស់ខ្លួន។

***៤.៣ ការសម្របសម្រួលឲ្យដើមបណ្ដឹងរដ្ឋប្បវេណីជនជាតិវៀតណាមអាចទទួលបានសញ្ជាតិខ្មែរ*** ៖ ទោះបីជាសហមេធាវីនាំមុខយល់ដឹងថា តុលាការពុំមានអំណាចចាប់បង្ខំឲ្យរាជរដ្ឋាភិបាលផ្ដល់សញ្ជាតិខ្មែរដល់ជនរងគ្រោះជានិគមជនជាតិវៀតណាមក៏ដោយ ក៏សហមេធាវីនាំមុខ **អេលីហ្សាប៉ែត ស៊ីម៉ុណូហ្វត** បានបញ្ជាក់ថា ការទាមទារនេះមិនមានចេតនាឈ្លានពានលើសមត្ថកិច្ចរបស់រដ្ឋាភិបាលនោះទេ។ ផ្ទុយទៅវិញ ការទាមទារនេះ ស្វែងរកការសម្របសម្រួលមួយដល់ការដាក់ពាក្យសុំរបស់ជនរងគ្រោះជាជនជាតិវៀតណាម ក្នុងការទទួលបានសញ្ជាតិខ្មែរ ដូចដែលមានចែងក្នុងច្បាប់តែប៉ុណ្ណោះ។ សំណើនេះរួមបញ្ចូលឲ្យមានជា ៖ កម្មវិធីអប់រំដល់ជនរងគ្រោះ អំពីច្បាប់ស្ដីពីសញ្ជាតិ ការជួយផ្ដល់ប្រឹក្សាអំពីលក្ខខណ្ឌដាក់ពាក្យសុំ ការដាក់ពាក្យសុំទៅនាយកដ្ឋានទទួលបន្ទុកនានា និងការសម្របសម្រួលជាមួយអាជ្ញាធរមូលដ្ឋាន ដោយជូនដំណឹងអំពីស្ថានភាពរបស់ជនជាតិវៀតណាមដែលបានតាំងខ្លួនជាជនរងគ្រោះ។

***៤.៤ ការវាយតម្លៃអំពីតម្រូវការ និងការបណ្ដុះបណ្ដាលជំនាញ*** ៖ គឺជាសំណើផ្សេងមួយទៀត ដែលត្រូវការក្រុមវាយតម្លៃអំពីតម្រូវការរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ជាពិសេសជនរងគ្រោះពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។

សំណើនេះ ក៏មានបញ្ចូលនូវវគ្គបណ្តុះបណ្តាលជំនាញ និងវិជ្ជាជីវៈ ព្រមទាំងផ្តល់ជាហិរញ្ញប្បទានខ្នាតតូចដល់ជនរងគ្រោះជាដើម។

### គ. ដែនសមត្ថកិច្ចរបស់ អ.វ.ត.ក ក្នុងការផ្តល់សំណង

នៅក្នុងអនុស្សារណៈចុះថ្ងៃទី២៣ កញ្ញា ស្តីពីការទាមទារសំណងបឋម អង្គជំនុំជម្រះសាលាដំបូង បានលើកឡើងថា គម្រោងមួយចំនួន រួមទាំងការបង្កើតគម្រោងមូលនិធិផ្តល់សំណង គឺស្ថិតនៅក្រៅក្របខណ្ឌច្បាប់នៃ អ.វ.ត.ក។ លើសពីនេះ អង្គជំនុំជម្រះសាលាដំបូងបានបន្ថែមថា សំណើសុំផ្សេងៗទៀត ដូចជាការបង្កើតទិវាចងចាំ អ.វ.ត.ក អាចយល់ព្រមអនុម័ត និងដាក់ជូនរដ្ឋាភិបាល ប៉ុន្តែពុំមែនជាសេចក្តីបង្គាប់នោះទេ ដោយសារថា រដ្ឋាភិបាលមានអំណាចផ្តាច់មុខ និងសមត្ថកិច្ចក្នុងការអនុវត្តសំណើទាំងនេះ។

ឆ្លើយតបទៅនឹងការកត់សម្គាល់នេះ មេធាវី **ហ្សាក់កាង** បានបញ្ជាក់ឡើងវិញថា បញ្ហាទាក់ទងនឹងអំណាចរបស់ អ.វ.ត.ក ក្នុងការផ្តល់សំណង គឺនៅតែជាចំណោទមួយនៅឡើយ ព្រោះនៅរង់ចាំសេចក្តីសម្រេចនៃប្តឹងឧទ្ធរណ៍នៅក្នុងសំណុំរឿង០០១។ នៅក្នុងបណ្តឹងឧទ្ធរណ៍ ដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង០០១ បានអះអាងថា ប្រសិនណា អ.វ.ត.ក មិនមានយុត្តាធិការតម្រូវឲ្យរដ្ឋាភិបាលកម្ពុជាផ្តល់សំណងនោះទេ ជនរងគ្រោះអាចនឹងដាក់បណ្តឹងទាមទារដោយផ្ទាល់ទៅជនចោទជាប់ ដែលនេះចាប់បង្ខំឲ្យមានការចូលរួមអន្តរាគមន៍ពីរដ្ឋាភិបាល។ លោកស្រីមេធាវីបានបន្ថែមទៀតថា ការប្តេជ្ញាចិត្តរបស់ព្រះរាជាណាចក្រកម្ពុជាក្នុងឆាកអន្តរជាតិ បានតម្រូវឲ្យរដ្ឋាភិបាលមានកាតព្វកិច្ចក្នុងការផ្តល់សំណងដល់ជនរងគ្រោះពីរបបខ្មែរក្រហម។

ពាក់ព័ន្ធនឹងសំណើសុំបង្កើតទិវាចងចាំ មេធាវី **សំ សុខគង់** បានសង្កត់ធ្ងន់ថា ពួកគេពុំបានស្នើសុំឲ្យ អ.វ.ត.ក បង្គាប់ឲ្យរដ្ឋាភិបាលអនុវត្តទៅតាមសំណើសុំនោះទេ ប៉ុន្តែ ពួកគេមានបំណងចូលរួមជាមួយរដ្ឋាភិបាល តាមរយៈអង្គភាពគាំទ្រជនរងគ្រោះ មុនពេលសំណើត្រូវបានសម្រេច ។ នាពេលបច្ចុប្បន្ន គឺគ្រាន់តែស្នើសុំឲ្យអង្គជំនុំជម្រះសាលាទទួលស្គាល់ថា មានសំណើនេះតែប៉ុណ្ណោះ។

ឆ្លើយតបនឹងសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី មេធាវី **ម៉ៃឃើល កាណាវ៉ាស** ដែលជាមេធាវីអន្តរជាតិការពារក្តីលោក **អៀង សារី** បានសម្តែងការគាំទ្រចំពោះសំណើមួយចំនួន ដូចជា ការសាងសង់វិមានអនុស្សាវរីយ៍ ការបង្កើតវិទ្យាស្ថានជំនួយផ្នែកច្បាប់ និងការបង្កើតកម្មវិធីអប់រំដែលបង្ហាញពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យឲ្យកាន់តែទូលំទូលាយ មិនត្រឹមតែជាព្រឹត្តិការណ៍នៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក។ តែទោះជាយ៉ាងណា លោកមេធាវីបានលើកថា គាត់មិនបានជំរុញឲ្យអង្គជំនុំជម្រះត្រូវតែសម្រេចផ្តល់សំណងទៅតាមសំណើទាំងអស់នោះទេ។ លោកមេធាវីបានបន្តថា សំណើសុំសំណង គឺត្រូវឆ្លុះបញ្ចាំងអំពីអ្វីដែលរដ្ឋាភិបាលគួរតែធ្វើឲ្យជាប្រយោជន៍ដល់ជនរងគ្រោះ និងពុំមែនជាអ្វីដែលអង្គជំនុំជម្រះសាលាដំបូងត្រូវបញ្ញត្តិដោយខ្លួនឯងនោះទេ។

ចំណែកឯមេធាវីការពារក្តីដទៃទៀត ក៏បានលើកឡើងពីក្តីបារម្ភរបស់ខ្លួនទាក់ទងនឹងសំណើមួយចំនួន ជាពិសេសទាក់ទងនឹងសំណើសម្រាប់ជនរងគ្រោះជាជនជាតិវៀតណាម។ មេធាវី **ផាត់ ពៅសៀង** ដែលជាមេធាវីជាតិការពារក្តីលោកស្រី **អៀង ធីរិទ្ធ** បានជំទាស់យ៉ាងខ្លាំង និងលើកសំអាងថា បញ្ហានេះហួសពីសមត្ថកិច្ចរបស់ អ.វ.ត.ក ក្នុងការផ្តល់

សំណាង ដែលនោះត្រូវកំណត់ដោយអាជ្ញាធររដ្ឋាភិបាលផ្អែកទៅតាមច្បាប់នៃប្រទេសកម្ពុជា។ ជាងនេះទៀត លោកមេធាវីបានបន្តលើកឡើងថា ជនជាតិវៀតណាមអាចត្រូវបែងចែកជាពីរក្រុម គឺ ***ជនអន្តោប្រវេសន៍ស្របច្បាប់*** និង ***ជនអន្តោប្រវេសន៍ខុសច្បាប់***។ លោកមេធាវីបានបន្ថែមថា អង្គជំនុំជម្រះសាលាដំបូងគួរពិចារណា ថាតើគួរផ្តល់សំណាងដល់ជនអន្តោប្រវេសន៍ខុសច្បាប់ដែរឬទេ។ គាត់បានសង្កត់ធ្ងន់ថា យោងតាមវិធាន ២៣ស្ទួនបួន បានចែងថា សំណាងគួរមានលក្ខណៈសមូហភាព និងផ្លូវចិត្ត ដូច្នេះសំណាងត្រូវតែផ្តល់ផលប្រយោជន៍ដល់ជនរងគ្រោះគ្រប់រូប និងមិនមែនសម្រាប់តែក្រុមមួយចំនួន ឬជាតិសាសន៍ ដូចជា និគមជនជាតិចាម ឬ វៀតណាមឡើយ។ លោកមេធាវីបានលើកសំអាងថា សំណាងដែលមានទំនោរទៅលើក្រុមនិគមជនជាតិមួយចំនួននោះ អាចនាំឲ្យប្រជាពលរដ្ឋឆ្ងល់ថា ហេតុអ្វីបានជាមិនមានសំណាងសម្រាប់ "ប្រជាជនកម្ពុជា" ផងដែរ។

ចំពោះលោក **អាង ឧត្តម** ដែលជាមេធាវីការពារក្តីលោក **អៀង សារី** បានលើកឡើងដោយប្រុងប្រយ័ត្នថា ការសម្រេចចិត្តរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីសំណាង ត្រូវតែស្របទៅតាមច្បាប់។ មេធាវីបានលើកឡើងថា នៅក្រោមច្បាប់កម្ពុជា ការផ្តល់សញ្ជាតិដល់ជនបរទេសអាចធ្វើទៅបាន តាមរយៈ (១) ទីកន្លែងកំណើតនៅក្នុងប្រទេសកម្ពុជា (២) ការរៀបអាពាហ៍ពិពាហ៍ជាមួយជនជាតិកម្ពុជា (៣) ការធ្វើវិនិយោគទុនក្នុងប្រទេសកម្ពុជា និង (៤) ការផ្តល់ជំនួយដល់រាជរដ្ឋាភិបាល។ លោកមេធាវីបានដាក់ជាចំណោទថា តើការផ្តល់សញ្ជាតិដល់ជនជាតិវៀតណាមឈរលើមូលដ្ឋានណាមួយ។

ជាការឆ្លើយតប សហមេធាវីនាំមុខ **ស៊ីម៉ូណូ ហ្វត** បានកត់សម្គាល់ថា ក្រុមមេធាវីការពារក្តីប្រហែលជាភ័ន្តច្រឡំទៅលើការទាមទារសំណង ជាពិសេស ការទាមទារទាក់ទងនឹងជនរងគ្រោះជាជនជាតិចាម និងវៀតណាម។ លោកស្រីមេធាវីបានរំឭកដល់ភាគីថា គម្រោងដែលបានស្នើឡើង គឺមានសារៈសំខាន់ស្មើគ្នា ហើយមិនមានគម្រោងណាមួយសំខាន់ជាងណាមួយនោះទេ។ លោកស្រីក៏បានទទួលស្គាល់ថា ទោះបីជាសំណើសុំសំណងទាំងនេះ ធ្វើឡើងសម្រាប់ប្រជាជនកម្ពុជាក៏ដោយ ក៏ដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗអាចនឹងទទួលបានផលប្រយោជន៍ផ្សេងៗគ្នាពីគម្រោងជាក់លាក់ទាំងនេះ។ លោកស្រីមេធាវីបន្តបញ្ជាក់ថា អំពីការទាមទាររបស់ជនរងគ្រោះជាជនជាតិវៀតណាម គឺពុំមែនសុំឲ្យអង្គជំនុំជម្រះផ្តល់សញ្ជាតិខ្មែរដល់ពួកគេនោះទេ ប៉ុន្តែសុំឲ្យមានការទទួលស្គាល់អំពីការទាមទារ និងជួយសម្របសម្រួលដល់ដំណើរការដាក់ពាក្យសុំសញ្ជាតិតែប៉ុណ្ណោះ។ លោកស្រីទទូចថា សំណើសុំជួយសម្រួលដំណើរការនេះ គឺពិតជាស្ថិតនៅក្នុងរង្វង់សមត្ថកិច្ចរបស់អង្គជំនុំជម្រះក្នុងការចេញសេចក្តីសម្រេចរបស់ខ្លួន ។

### ឃ. តម្រូវការនៃសំណាងប្រកបដោយអត្ថន័យ

នៅចុងបញ្ចប់នៃសវនាការ សហមេធាវីនាំមុខ **ស៊ីម៉ូណូ ហ្វត** បានថ្លែងអំណរគុណដល់អង្គជំនុំជម្រះក្នុងការផ្តល់ឱកាសបន្ថែមក្នុងការរៀបចំសំណើឲ្យកាន់តែលម្អិត។ លោកស្រីមេធាវីបានសង្កត់ធ្ងន់ អំពីសារៈសំខាន់នៃសំណាងនៅក្នុងដំណើរការយុត្តិធម៌ និងអំពីតម្រូវការនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី គឺដើម្បីទទួលបានយុត្តិធម៌ក្នុងនាមប្រជាជនកម្ពុជាទាំងមូល។ លោកស្រីបានបញ្ជាក់ថា ភាគីដើមបណ្តឹងរដ្ឋប្បវេណី គឺតំណាងឲ្យជនរងគ្រោះទាំងឡាយពីរបបដ៏យង់ឃ្នងនេះ។

ដូចគ្នានេះដែរ លោកស្រីមេធាវី **ស៊ីម៉ូណូ ហ្វត** បានគូសបញ្ជាក់អំពីសារៈសំខាន់ក្នុងការទទួលបានសំណាងប្រកប

ដោយអត្ថន័យនៅក្នុងដំណើរការស្វែងរកយុត្តិធម៌នេះ ទោះបីជាជួបប្រទះឧបសគ្គ ដូចជា ការពិភាក្សាដេញដោលលើបញ្ហាមួយចំនួន ឬក៏ការធ្វើឲ្យពន្យារពេលសវនាការក៏ដោយ។ លោកស្រីមេធាវីបានសង្កត់ធ្ងន់ថា សំណងពុំមែនជាវិធានការងាយស្រួល និងអាចអនុវត្តបានដោយភ្លាមៗនោះទេ។ សំណងត្រូវតែបំពេញចិត្តដល់ដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗ ដែលធ្វើឲ្យពួកគេមានអារម្មណ៍ថា ពួកគេទទួលបានសំណងមួយដែលអាចឆ្លើយតបនឹងការឈឺចាប់របស់ខ្លួន ហើយវានឹងមិនមានសារៈសំខាន់ទេ ប្រសិនណាបើ ដើមបណ្តឹងរដ្ឋប្បវេណីពុំបានយល់អំពីអត្ថន័យ និងលទ្ធផលនៃសំណងទាំងនោះ។ លោកស្រីបានដកស្រង់សេចក្តីវិនិច្ឆ័យរបស់អង្គបុរេជំនុំជម្រះនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ នៅក្នុងករណីលោក **លូបាងហ្គា ឌីយ៉ីឡូ** ដែលប្រកាសថា "ជោគជ័យរបស់តុលាការត្រូវផ្សាភ្ជាប់ជាមួយនឹងជោគជ័យនៃប្រព័ន្ធផ្តល់សំណង"[ix]។

លោកស្រីមេធាវីបន្តបញ្ជាក់ថា សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានយល់ដឹងអំពីសំណូមពររបស់ពួកគេថា ពិតជាមានមហិច្ឆតាខ្ពស់ ហើយមានការលំបាកក្នុងការអនុវត្តន៍ ប៉ុន្តែ លោកស្រីបានលើកហេតុផលថា ប្រសិនណាបើពួកគេពុំបានលើកនូវសំណើទាំងនោះទេ វាហាក់ដូចជាពួកគេមិនបានតំណាងជនរងគ្រោះឲ្យអស់ពីលទ្ធភាព។ លោកស្រីមេធាវីបានតវ៉ាទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះលើកមុន ហើយបានលើកឡើងថា "សំណើសុំសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែខ្ពស់ ហើយអង្គជំនុំជម្រះត្រូវតែសម្រេចផ្តល់សំណងទាំងនេះ ព្រោះជាវិធានការវិសាមញ្ញ"។ ការធ្វើបែបនេះគឺដើម្បីធានាថា ទម្រង់នៃសំណងត្រូវតែប្រកបដោយអត្ថន័យ និងមានសារៈប្រយោជន៍ ដែលពុំធ្វើឲ្យដើមបណ្តឹងរដ្ឋប្បវេណីមានអារម្មណ៍អាក់អន់ស្រពន់ចិត្ត ចំពោះការសម្រេចរបស់អង្គជំនុំជម្រះឡើយ។

សហព្រះរាជអាជ្ញា បានសម្តែងនូវការគាំទ្រចំពោះការទាមទារសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងបានបញ្ជាក់អំពីតម្រូវការនៃសំណងប្រកបដោយអត្ថ័យ។ សហព្រះរាជអាជ្ញាបានបន្តថា យុត្តិធម៌ត្រូវតែផ្តល់ដល់ជនរងគ្រោះ ក្នុងករណីដែលមានការផ្តន្ទាទោស ព្រមទាំងទទួលស្គាល់ពីសារសំខាន់នៃការផ្តល់សំណងប្រកបដោយអត្ថន័យ ទោះបីជាសំណងទាំងនោះមានលក្ខណៈជា សមូហភាព ឬ ផ្លូវចិត្តក៏ដោយ។ សហព្រះរាជអាជ្ញា បានឲ្យដឹងថា ដើមបណ្តឹងរដ្ឋប្បវេណីពុំមែនត្រឹមតែតំណាងឲ្យខ្លួនឯងប៉ុណ្ណោះទេ តែពួកគេតំណាងឲ្យជនរងគ្រោះទូទាំងប្រទេសនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលពុំបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ដូច្នេះ ការផ្តល់សំណងដែលត្រឹមតែការបោះពុម្ពផ្សព្វផ្សាយឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី ពុំគ្រប់គ្រាន់នោះទេ។ សហព្រះរាជអាជ្ញា បានបន្ថែមថា អង្គជំនុំជម្រះត្រូវតែសម្រេចទៅតាមសំណើ ដែលបានលើកឡើង និងមានអត្ថប្រយោជន៍ទាំងនេះ ហើយសំណងទាំងនេះត្រូវតែអនុវត្តនៅមុនពេល អ.វ.ត.ក បញ្ចប់អណត្តិរបស់ខ្លួន។ សហព្រះរាជអាជ្ញាបានរំឭកថា ប្រសិនណាបើសំណងប្រកបដោយអត្ថន័យពុំអាចផ្តល់ឲ្យជនរងគ្រោះនោះទេ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះនឹងពុំមានន័យខ្លឹមសារឡើយ។ តែទោះជាយ៉ាងណា សហព្រះរាជអាជ្ញាទទួលស្គាល់ថា សំណើសុំសំណងត្រូវតែស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ អ.វ.ត.ក។

ដូចបានបញ្ជាក់នៅខាងដើម ក្រុមមេធាវីការពារក្តី បានបន្តចោទសួរអំពីដែនសមត្ថកិច្ចរបស់ អ.វ.ត.ក ក្នុងការផ្តល់នូវសំណងជាក់លាក់ទាំងនេះ។ ក្រុមមេធាវីលើកទឡ្ហីករណ៍ថា សំណើសុំសំណងមួយចំនួនធំ គឺស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋាភិបាលក្នុងការអនុញ្ញាត និងការអនុវត្ត។

## III. ការគ្រប់គ្រងសវនាការ

លោកប្រធានអង្គជំនុំជម្រះ **និល ណុន** បានគ្រប់គ្រងសវនាការបានយ៉ាងជាក់លាក់ក្នុងការកម្រិតការពិភាក្សារបស់ភាគីមិនឲ្យហួសពីរបៀបវារៈ។ តួយ៉ាង សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី មានបំណងលើកឡើងពីបញ្ហានៃការបែងចែកកិច្ចដំណើរនីតិវិធី និងពន្យល់អំពីការជះឥទ្ធិពលទៅដល់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែអង្គជំនុំជម្រះពុំបានអនុញ្ញាតឲ្យលើកឡើងនោះឡើយ។

**ក. វត្តមានរបស់ជនជាប់ចោទ**

មានតែជនជាប់ចោទ លោកស្រី **អៀង ធីរិទ្ធ** លោក **អៀង សារី** និងលោក **នួន ជា** ដែលមានវត្តមាននៅពេលសវនាការ។ ប៉ុន្តែជនជាប់ចោទ **អៀង សារី** បានសុំចាកចេញពីបន្ទប់សវនាការ បន្ទាប់ពីដំណើរការបានប្រព្រឹត្តទៅបានប្រហែលជាមួយម៉ោង។ ចំណែកឯជនជាប់ចោទ **នួន ជា** ក៏បានសុំចាកចេញដែរ ដោយសារតែបញ្ហាសម្ពាធឈាមឡើងខ្ពស់ និងការឈឺក្បាល នៅវេលាម៉ោង ១០.២៥ព្រឹក។

**ខ. វត្តមានរបស់សាធារណជន**

ដើមបណ្តឹងរដ្ឋប្បវេណីប្រហែលជា ១០រូប មានវត្តមាននៅក្នុងបន្ទប់សវនាការ ចំណែកនៅឯសាលសាធារណៈវិញ មានសាធារណជនប្រហែលជា ៥០រូប ក្នុងនោះរួមមាន ដើមបណ្តឹងមួយចំនួន តំណាងអង្គការមិនមែនរដ្ឋាភិបាល អ្នកសារព័ត៌មាន និងសិស្សនិស្សិត។

**គ. បញ្ហានៃការបកប្រែ**

ជាទូទៅ ការបកប្រែបានដំណើរការដោយរលូន ទោះបីជាពេលខ្លះភាគីបាននិយាយលឿន រហូតធ្វើឲ្យអ្នកបកប្រែពុំអាចតាមទាន់ ហើយនេះប្រហែលជាអាចនាំឲ្យមានការបាត់បង់នូវខ្លឹមសារមួយចំនួន។ ចំណែកឯនៅចុងបញ្ចប់នៃសវនាការ ប្រធានអង្គជំនុំជម្រះបានឲ្យអ្នកបកប្រែកែតម្រូវពីការជូនដំណឹង អំពីការផ្តល់ពេលវេលាដល់ភាគីនៅក្នុងសវនាការនាពេលរសៀល។

**ឃ. ការគ្រប់គ្រងពេលវេលា**

| កាលបរិច្ឆេទ | ចាប់ផ្តើម | ការសម្រាកពេលព្រឹក | អាហារថ្ងៃត្រង់ | ការសម្រាកពេលរសៀល | បិទសវនាការ | ចំនួនម៉ោងសរុប |
|---|---|---|---|---|---|---|
| ថ្ងៃពុធ ១៩/១០/១១ | ០៩.០០ | ១០.២១ - ១០.៤៨ | ១១.៥៧ | - | - | ២ ម៉ោង និង ២៩ នាទី |
| ចំនួនម៉ោងជាមធ្យមក្នុងសវនាការមួយវគ្គ ៖ ២ ម៉ោង ២៩ នាទី | | | | | | |

* This report was authored by Mary Kristerie A. Baleva, Samuel Gilg, Princess Principe, Noyel Ry, Kimsan Soy, Penelope Van Tuyl and Flavia Widmer as part of AIJI"s KRT Trial Monitoring and Community Outreach Program. AIJI is a collaborative project between the East-West Center, in Honolulu, and the University of California, Berkeley War Crimes Studies Center. Since 2003, the two Centers have been collaborating on projects relating to the establishment of justice initiatives and capacity-building programs in the human rights sector in South-East Asia..

---

[i] Trial Chamber. "Memorandum on Initial Specification of the Substance of the Reparations Awards sought by the Civil Party Lead Co-Lawyers pursuant to Internal Rule 23quinquies(3)" (23 September 2011). E125 [hereinafter, **MEMORANDUM ON INITIAL SPECIFICATION OF THE SUBSTANCE OF REPARATIONS AWARDS**]. p.3. The Trial Chamber observed that some reparations awards sought is outside the scope of the ECCC legal framework and would require specific government approval or authorization. It also stated that some measures sought lacked sufficient specificity for the Trial Chamber to comment.

[ii] Trial Chamber. "Scheduling Order for Hearings on 19 and 20 October 2011 (10 October 2011). E129 [hereinafter, **SCHEDULING ORDER**]. p. 3.

[iii] MEMORANDUM ON INITIAL SPECIFICATION OF THE SUBSTANCE OF REPARATIONS AWARDS. p.3.

[iv] Under Internal Rule 12 *ter* (as amended on 23 February 2011), the task of organizing civil party representation fall on the National and International Civil Party Lead Co-Lawyers, who are to consult and coordinate with the lawyers of the civil parties

[v] *Case of the Mapiripan Massacre v. Colombia*. Inter-American Court of Human Rights. "Judgment of September 15, 2006 (Merits, Reparations and Costs)(15 September 2006).

[vi] Ibid. par. 285.156.

[vii] Ibid. par. 315. 169.

[viii] Case 001. Trial Chamber. "Judgement" (26 July 2010). par. 670-71

[ix] See *Prosecutor vs. Thomas Lubanga Dyilo*. ICC-01/04-01/06. ICC Pre-Trial Chamber I. Decision (17 January 2006).